ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៧៦

ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣

<u>សាលដីកា</u>

លេខ : ៦៧ (ថ)

ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤។

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោកស្រី [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

-ដើមចោទឈ្មោះ [redacted] គឺមជា "ម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៧០ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ២៩E₁ ផ្លូវលេខ៥៥៤ ក្រុម៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មានមេធាវីលោក [redacted] តំណាងដោយអាណត្តិ

និងសហចុងចម្លើយ

៧៦២



Scanned with CamScanner

4/04

១-ឈ្មោះ [redacted] សាវ៉ែន "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៩ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ២៩$E_1$ ផ្លូវលេខ៥៥៤ ក្រុម៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

២-ឈ្មោះ [redacted] សុភាលី "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ មានទីលំនៅផ្ទះលេខ២៩$E_0$ ផ្លូវលេខ៥៥៤ ក្រុម៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

៣-ឈ្មោះ [redacted] ចាន់ណារី "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរនៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះលេខ២៩$E_0$ ផ្លូវលេខ៥៥៤ ក្រុម៣៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

<u>កម្មវត្ថុបណ្តឹង</u> : ប្តឹងសុំអោយតុលាការចេញសាលក្រមអោយចុងចម្លើយរុះរើរបងស័ង្កសី ដែលហ៊ុំព័ទ្ធលើដីមានទំនាស់ទំហំ៥.៨០មx៦.៨០ម ស្ថិតនៅដីឡូត៍លេខ២៩ ក្រុម៣៧ ផ្លូវលេខ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

## អំពីអង្គហេតុ និង ចំណុចទាមទារ :

### ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ</u>

ដើមចោទឈ្មោះ [redacted] គឹមថា ប្តឹងសុំអោយតុលាការចេញសាលក្រមអោយចុងចម្លើយរុះរើរបងស័ង្កសី ដែលហ៊ុំព័ទ្ធលើដីកំពុងមានទំនាស់អោយដីនៅសភាពដើមដដែល រង់ចាំរកម្ចាស់កម្មសិទ្ធិពិតប្រាកដសិន។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ០៧ "គ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ៖

១-ច្រានចោលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] គឹមថា ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១១ ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

២-ប្រគល់ដីទំហំ៤,៨០ម៉ែត្រគុណ៦,៨០ម៉ែត្រ ស្ថិតនៅដីឡូត៍លេខ២៩ ក្រុម៣៧ ផ្លូវលេខ៥៥៤ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឲ្យចុងចម្លើយឈ្មោះ [redacted] សាវ៉ែន ឈ្មោះ [redacted] ស៊ីអ៊ី ប្រពន្ធឈ្មោះ [redacted] ចាន់ណារី និងឈ្មោះ [redacted] វណ្ណា ប្រពន្ធឈ្មោះ [redacted] សុភាលី ទុកប្រើប្រាស់ជាប្រយោជន៍រួម។

៣-ប្រាក់ពន្ធជាបន្ទុករបស់ដើមចោទ។

៤-សាលក្រមនេះបានទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់គិតពីថ្ងៃបានទទួលការបញ្ជូនអនុសារសាលក្រម។

២៦៣



Scanned with CamScanner

4"
03

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦១ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] គឹមថា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ០៧ "គ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២១ "ក្រ.៥.ប" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ៖

១-ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ៦១ ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់ដើមចោទឈ្មោះ [redacted] គឹមថា។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៧ "គ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៤-សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣។

-បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេល០១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

បានឃើញបណ្តឹងសាទុក្ខលេខ១៨៣ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] គឹមថា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២១ "ក្រ.៥.ប" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

## ខ - <u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី</u>

-បានស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកស្រី [redacted] គឹមថា នាពេលសវនាការថា: ខ្លួនបានគ្រប់គ្រងដីទំហំ២០មx៣០ម ដែលមានផ្ទះទំហំ១៨មx១២ម សង់អំពីថ្មក្រោម ឈើលើ មានជណ្តើរសម្រាប់ឡើងទៅជាន់ទីមួយ នៅក្បែរជណ្តើរនោះ ក្រុមគ្រួសាររបស់ខ្លួនបានធ្វើបន្ទប់សម្រាប់ដាក់សម្ភារៈផ្សេងៗ ក្រោយមកដោយបន្ទប់នោះចាស់ទ្រុឌទ្រោម ទើបធ្វើការវាយចោល និងធ្វើការសាងសង់ឡើងវិញ ទើបមានឈ្មោះបីគ្រួសារនេះជំទាស់។ ដីឡូត៍នេះពីមុនមានតែពីគ្រួសារ តែឥឡូវមានចំនួន៧គ្រួសារ ខាងក្រោម៥គ្រួសារ ខាងលើពីរគ្រួសារ ហើយខ្លួននៅខាងក្រោយ។ ដីទំនាស់ដីគឺនៅជុំវិញផ្ទះ សព្វថ្ងៃខ្លួនមានច្រកចេញ-ចូល គេទុកឲ្យ១ម៉ែត្រ។

<u>សំណូមពរ:</u> សុំឲ្យរុះរើរបងចេញពីដីទំនាស់។

-បានស្តាប់សេចក្តីថ្លែងការណ៍របស់ប្តីអ្នកស្រី [redacted] សុភាលី នាពេលសវនាការថា: ដីទំនាស់ទំហំ៤,៨មx៦,៨ នេះ គឺជាដីរួមរបស់៤គ្រួសារ ព្រោះដីទំនាស់នេះពីមុនជាដីផ្ទុកមានភក់ជ្រាំស្អុយរលួយ។ ហើយពួកខ្លួនទាំង៤គ្រួសារបានសំរេចចិត្តឯកភាពគ្នាទិញដីចាក់លុបផ្ទុកដោយគ្រួសារ [illegible] គឹមឈួម និង [redacted] គឹមថា មិនដឹងឮ និងមិនចូលជាថវិការសំរេចចាក់លុបដីផ្ទុកនោះទេ។ [illegible]

២៦៤



264

ដល់ឥឡូវពួកខ្លួនបានលក់អោយឈ្មោះ [redacted] ដារ៉ា អស់ហើយ ចំណែកឈ្មោះ [redacted] គីមថា នៅលើគាត់ទារសុទ្ធតែ១៧ម៉ឺនដុល្លាអាមេរិក។

-បានស្តាប់សេចក្តីថ្លែងការណ៍របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយដើមចោទនាពេលសវនាការថា: ដីមានទំនាស់នេះកូនក្តីខ្លួនបានគ្រប់គ្រងតាំងពីឆ្នាំ១៩៨៤មក តែពុំមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អ្វីទេ ដោយនៅក្បែរជណ្តើរក្រុមគ្រួសាររបស់កូនក្តីខ្លួនបានធ្វើជាបន្ទប់សម្រាប់ដាក់សម្ភារៈផ្សេងៗ ក្រោយមកដោយបន្ទប់នោះចាស់ទ្រុឌទ្រោម កូនក្តីខ្លួនបានរុះរើសាងសង់ថ្មីឡើងវិញ ក៏ត្រូវបានចុងចម្លើយដាក់ពាក្យបណ្តឹងមកតុលាការសុំដីកាសម្រេចរក្សាការពារ និងអនុវត្តរុះរើបន្ទប់របស់កូនក្តីខ្លួនអស់ ក្រោយមកចុងចម្លើយបាននាំគ្នាយកស័ង្កសីទៅហ៊ុំព័ទ្ធលើដីនេះអស់។

សំណូមពរ: សុំឱ្យចុងចម្លើយរុះរើស័ង្កសីចេញពីដីកំពុងមានទំនាស់នេះ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាង ដោយអាណត្តិឱ្យដើមចោទ.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៨៣ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] គីមថា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតំកល់សាលក្រមរដ្ឋប្បវេណីលេខ០៧ "គ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែលនោះ គឺពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ពីព្រោះថា៖

ដើមចោទគ្រាន់តែសុំឱ្យមានការរុះរើរបងស័ង្កសី ដែលហ៊ុំព័ទ្ធលើដីទំនាស់អោយនៅសភាពដើមដដែល ក្រោយពីមានការចុះអនុវត្តដីការក្សាការពារពីមុនមកតែប៉ុណ្ណោះ។ ហើយម្យ៉ាងវិញទៀតចុងចម្លើយមិនបានដាក់ពាក្យបណ្តឹងតប ដើម្បីទាមទារដីទំនាស់ទំហំ៤,៨០ម៉ែត្រ x ៦,៨០ម៉ែត្រ នេះមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនទេ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២១ "ក្រ.៥.ប" ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ ពុំមានភាពត្រឹមត្រូវតាមគតិច្បាប់ទេ។



Scanned with CamScanner

41

## ហេតុដូច្នេះ

## ទនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ១៨៣ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៣ របស់ឈ្មោះ[redacted]គីមថា។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ២១ “ក្រ.៥.ប” ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ១៧៦ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូល ជាបន្ទុករបស់ភាគីសហចុងចម្លើយ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| លោក | | ជាចៅក្រម |
| លោក | | ជាចៅក្រម |
| លោក | | ជាចៅក្រម |
| លោកស្រី | | ជាចៅក្រម |
| លោក | | ក្រឡាបញ្ជី |

បានឃើញ
ភ្នំពេញ ថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០១៤
ប្រធាន

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ភ្នំពេញ ថ្ងៃទី១ ខែ ឆ្នាំ ២០១៤

[redacted]



266